រាជធានីភ្នំពេញ ថ្ងៃពុធ ០៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

# សេចក្តីប្រកាសព័ត៌មានរួម
# ស្តីពី
# ការអំពាវនាវឲ្យមានការពន្លឿន និងផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិលបន្តចូលរួម ក្នុងដំណើរការ វិសោធនកម្មច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលចំនួន ៧៥ ដែលបានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីសំណើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលប្រារព្ធធ្វើនៅ សណ្ឋាគារសាន់វេយ៍ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ និងបានចូលរួមសិក្ខាសាលានៅតាមបណ្តាខេត្ត ក៏ដូចជាតំណាងសមាគម និងអង្គការដែលបានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងាររាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ សូមសម្តែងការសាទរចំពោះកិច្ចពិគ្រោះយោបល់ ស្តីពីសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលដឹកនាំដោយក្រសួងមហាផ្ទៃ ដែលបានផ្តល់ឱកាសឱ្យសង្គមស៊ីវិលបកស្រាយ និងលើកឡើងនូវអនុសាសន៍ប្រកបដោយមេត្រីភាពក្នុងន័យភាពជាដៃគូកន្លងមក។

កិច្ចប្រជុំពិគ្រោះយោបល់ខាងលើ មានចំនួនប្រាំមួយ(០៦)លើក ដែលបានអនុញ្ញាតឱ្យអង្គការសង្គមស៊ីវិល បានដាក់ជូនសំណើជាផ្លូវការ និងលើកឡើងដោយផ្ទាល់អំពីមតិយោបល់ ក៏ដូចជាកង្វល់លើមាត្រាចំនួន១៤ ដែលក្នុងនោះស្នើឲ្យមានការកែសំរួលពាក្យពេជន៍ បន្ថែម ឬបន្ថយនូវវាក្យខណ្ឌមួយចំនួនលើ ១២មាត្រា និងស្នើលុបចោលទាំងស្រុងចំនួន២មាត្រា (មាត្រា២៤ និងមាត្រា៣២)។ បើទោះបីជាមានកិច្ចប្រជុំចំនួនប្រាំមួយ (០៦) លើករួចហើយក៏ដោយ តែតំណាងអង្គការសង្គមស៊ីវិល និងក្រសួងមហាផ្ទៃនៅមិនទាន់បានសម្រេចលើការព្រមព្រៀងគ្នាលើខ្លឹមសារសំណើវិសោធនកម្មលើមាត្រាណាមួយឡើយ ក្នុងចំណោមមាត្រាទាំង១៤ដែលបានជជែកពិភាក្សាក្នុងកិច្ចប្រជុំទាំងនោះ។

តាមរយៈកិច្ចប្រជុំចំនួនប្រាំមួយលើកកន្លងមក សំណើវិសោធនកម្មជាផ្លូវការ និងសិក្ខាសាលាពិគ្រោះយោបល់ដែលរៀបចំដោយអង្គការសង្គមស៊ីវិល នៅថ្នាក់ជាតិនាពេលនេះ និងនៅតាមបណ្តាខេត្តនាពេលកន្លងមក បានបញ្ជាក់ជូនក្រុមការងារដែលដឹកនាំដោយក្រសួងមហាផ្ទៃពីការព្រួយបារម្ភដោយសង្ខេបជារួមដូចខាងក្រោម៖

- ការវិនិច្ឆ័យទុកជាមុន អំពីការធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថេរភាព សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ និងប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមកម្ពុជា សម្រាប់បង្កើតទៅជាមូលដ្ឋានលើការបដិសេធការចុះបញ្ជីរបស់អង្គការ សមាគម។
- ការកំណត់កាតព្វកិច្ចផ្តល់ព័ត៌មានគណនីធនាគារ ដែលរំលោភលើសិទ្ធិស្វ័យភាពនិងឯកជនភាពរបស់នីតិបុគ្គល។
- ការតម្រូវឱ្យចុះបញ្ជីសម្រាប់ក្រុមនីតិបុគ្គលដែលធ្វើការងារជាក្រុមលើការងារចំពោះកិច្ចជារួមរបស់ពួកគេ ដែលមានរយៈពេលមិនអចិន្ត្រៃយ៍ និងគ្មានអង្គការលេខចាត់តាំងច្បាស់លាស់។
- ការតម្រូវឱ្យប្រកាន់ជំហរអព្យាក្រឹត្យចំពោះគ្រប់គណបក្សនយោបាយ។ ប្រការនេះមានភាពអវិជ្ជមានយ៉ាងខ្លាំងចំពោះការអនុវត្តការងាររបស់អង្គការសង្គមស៊ីវិល ព្រោះពាក្យ«អព្យាក្រឹត្យ» នេះអាចផ្តល់ឱកាសឱ្យមន្ត្រីរដ្ឋាភិបាលធ្វើការបកស្រាយតាមកាលៈទេសៈ ឬតាមស្ថានភាពនយោបាយ។

- ការតម្រូវដោយរដ្ឋបាលថ្នាក់ក្រោមជាតិនានាឲ្យអង្គការសង្គមស៊ីវិលដាក់របាយការណ៍បន្ថែម គឺជាការអនុវត្ត ហួសពីកាតព្វកិច្ចដែលមានចែងក្នុងច្បាប់។
- ការតម្រូវដោយអាជ្ញាធរឲ្យជូនដំណឹង ឬសុំច្បាប់ពីអាជ្ញាធរសាធារណៈមានសមត្ថកិច្ចជាមុន អំពីការធ្វើសកម្មភាពនានា ប៉ុន្តែនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលភិបាល គ្មានបទប្បញ្ញត្តិណាមួយចែងអំពីកាតព្វកិច្ចនេះឡើយ ហើយស.ជ.ណ. លេខ២០០៦ របស់ក្រសួងមហាផ្ទៃ ក៏មិនតម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសុំច្បាប់ជាមុនដែរ ។
- ការកំណត់លក្ខខណ្ឌកាន់តែតឹងតែងសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដើម្បីទទួលបាន និងបន្តសុពលភាពនៃអនុស្សារណៈយោគយល់ ដោយរើសអើងទៅលើប្រភពដើមនៃមូលនិធិ និងការវិនិច្ឆ័យទៅលើចរិតលក្ខណៈនៃសកម្មភាពរបស់ពួកគេ ។ល។

បទប្បញ្ញត្តិច្បាប់ និងការអនុវត្តរបស់អាជ្ញាធរទាំងនេះធ្វើឱ្យមានប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិ និងសេរីភាពនៃការបង្កើត សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាការអនុវត្តសកម្មភាព និងសហប្រតិបត្តិការរបស់សង្គមស៊ីវិលដើម្បីលើកកម្ពស់ប្រជាធិបតេយ្យ ការការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម នៅកម្ពុជា។ ដោយផ្អែកលើបញ្ហាប្រឈម និងសំណើវិសោធនកម្មដែលបានដាក់ជូន និងជជែកពិភាក្សាជាមួយក្រសួងមហាផ្ទៃកន្លងមក ជាថ្មីម្តងទៀតអង្គការសង្គមស៊ីវិល ស្នើសុំយ៉ាងទទូចដល់ក្រុមការងាររាជរដ្ឋាភិបាលដែលដឹកនាំដោយក្រសួងមហាផ្ទៃដូចខាងក្រោម៖

១. ធ្វើវិសោធនកម្មលើមាត្រាទាំង១៤ រួមមានមាត្រា ១, មាត្រា ៧, មាត្រា ៨, មាត្រា ៩, មាត្រា ១០, មាត្រា ១១, មាត្រា ២០, មាត្រា ២៤, មាត្រា ២៥, មាត្រា ២៦, មាត្រា ៣០, មាត្រា ៣១, មាត្រា ៣២ និងមាត្រា ៣៥ ជាការព្រួយបារម្ភ ដែលបានលើកឡើងស្នើសុំធ្វើវិសោធនកម្មពីក្រុមអង្គការសង្គមស៊ីវិល។

២. ពន្លឿនការតាក់តែងសេចក្តីព្រាងច្បាប់ និងការធ្វើវិសោធនកម្មច្បាប់ឱ្យបានឆាប់រហ័សបំផុត និងដោយមានផែនការច្បាស់លាស់ ។

៣.ផ្តល់ឱ្យសង្គមស៊ីវិលបានសិក្សាបន្ថែមលើខ្លឹមសារដែលនឹងត្រូវបានតាក់តែងនៅក្នុងសេចក្តីព្រាងច្បាប់វិសោធនកម្ម នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៤.បន្តសហការជជែកពិភាក្សាជាមួយសង្គមស៊ីវិលលើខ្លឹមសារជាក់ស្តែងនៃសេចក្តីព្រាងច្បាប់វិសោធនកម្មនេះ ប្រកបដោយបរិយាបន្នក្នុងដំណាក់កាលជាបន្តបន្ទាប់ រហូតដល់សេចក្តីព្រាងច្បាប់វិសោធនកម្មទាំងមូលត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ ។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

| ឈ្មោះ: | ទូរស័ព្ទ: |
|---|---|
| ១. លោក សេង រិទ្ធី (PDP-Center) | ០១៧ ៦៨១ ៨៨០ |
| ២. លោក គន សាវាង្ស (COMFREL) | ០១១ ៨៨៤ ៨៤០ |
| ៣. លោក រី សុវណ្ណា (CCC) | ០៩៦ ៣៦៩ ៤៨០០ |
| ៤. លោក យូ ភឿន (NGO Forum) | ០១៧ ៥៧៥ ៨០៨ |
| ៥. លោកស្រី ហ៊ុន ស៊ីនួន (CRC-Cambodia) | ០៧៧ ៥៨៤ ០០៨ |
| ៦. លោក ចេង សារឿន (CCFC) | ០៧៨ ២២៥ ០៨៨ |